ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**លិខិតអបអរសាទរ**
**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**
**នៃព្រះរាជាណាចក្រកម្ពុជា**

***សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត!***

ក្នុងនាមថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ យើងខ្ញុំសូមសំដែងនូវការអបអរសាទរដ៏ខ្ពង់ខ្ពស់ និង កោតសរសើរយ៉ាងជ្រាលជ្រៅបំផុត ក្នុងឱកាសដែល **សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា** ទទួលបាននូវពានរង្វាន់ **សន្តិភាព និងការអភិវឌ្ឍ** ពី **សហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ាន** (UMA) នាព្រឹកថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១៦ នៅវិមានរដ្ឋសភា រាជធានីភ្នំពេញ ។

ពានរង្វាន់នេះ ជាសក្ខីភាពមិនអាចប្រកែកបាន នូវការតស៊ូប្រកបដោយមនសិការស្រឡាញ់សន្តិភាព និង ការអភិវឌ្ឍ របស់ **សម្តេចអគ្គមហាពញាចក្រី** ដែលបានចូលរួមចំណែកយ៉ាងធំធេង ក្នុងការរំដោះប្រទេសជាតិ និងប្រែក្លាយប្រទេសកម្ពុជា ឱ្យទៅជាប្រទេសមានសន្តិភាពពេញលេញ ស្ថិរភាពនយោបាយនិងសង្គម-សេដ្ឋកិច្ច ជាពិសេស លទ្ធិប្រជាធិបតេយ្យ-ពហុបក្ស ។ យើងខ្ញុំទាំងអស់គ្នា មានមោទនភាពដ៏ខ្ពង់ខ្ពស់បំផុត ដែលសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានទទួលនូវពានរង្វាន់ដ៏មានអត្ថន័យថ្លៃថ្លា សម្រាប់ជាកិត្តិយសដ៏ឧត្តុង្គឧត្តមរបស់កម្ពុជា ទាំងនៅលើឆាកជាតិ និងអន្តរជាតិ ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមគោរពជូនពរសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និង លោកជំទាវ ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតរបស់យើងខ្ញុំ

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom . khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798